# វប្បធម៌សន្ទនា - រិះគន់ , វប្បធម៌ហិង្សា - សំឡុត

# និង វប្បធម៌ឃុបឃិត - គាំទ្រ

នៅក្នុងពេលពិធីចែកសញ្ញាបត្រដល់និស្សិតនៅថ្ងៃទី៤ ធ្នូ លោក ហ៊ុន សែន បានថ្លែងថា អ្នកនយោបាយគួរបញ្ចប់នូវវប្បធម៌រិះគន់គ្នា ដោយលោកចង់ឲ្យមានវប្បធម៌សន្ទនាវិញ ។ លោក ហ៊ុន សែន បានទាំងគំរាមថា អនុប្រធានទី១រដ្ឋសភា (លោកកឹមសុខា) គួរប្រយ័ត្នខ្លួន ព្រោះសមាជិកសភាភាគច្រើនជារបស់លោក ហើយសភាអាចបុកទម្លាក់ពីតំណែងបាន ដោយ សំឡេងភាគច្រើន ។ លោកបន្តថា គេឲ្យតំណែងអនុប្រធានសភាទី១ ដើម្បីសម្របសម្រួល កិច្ចការជាមួយតំណាងរាស្ត្រក្នុងសភា មិនមែនសម្រាប់ដើរជេរគេជេរឯងនោះទេ ។

លោក ហ៊ុន សែន កាន់អំណាច និង ងារនាយករដ្ឋមន្ត្រីក្នុងចំណោមអ្នកកាន់អំណាចយូរជាងគេក្នុងលោក តែលោកមិនយល់ពីអ្វីទៅ ដែលហៅថាលទ្ធិប្រជាធិបតេយ្យ ដែលលោក និង សមាជិកសភារបស់គណបក្សប្រជាជនកម្ពុជារបស់លោកតែងតែស្រែកថា ប្រទេសកម្ពុជា ជាប្រទេសគោរពលទ្ធិប្រជាធិបតេយ្យពហុបក្ស ដូចមានចែងនៅក្នុង រដ្ឋធម្មនុញ្ញពីឆ្នាំ ១៩៩៣ ។

លទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេស និង នៅក្នុងបក្សក៏ដោយ បុគ្គលម្នាក់ៗមានសិទ្ធិសេរីភាពក្នុងការបញ្ចេញយោបល់ មានការទំនាក់ទំនង ឬ ស្តាប់យោបល់អ្នកដ៏ទៃ ។ ទង្វើអស់នេះជាធនធានក្នុងការពិចារណា និង ជូនយោបល់ទៅប្រជាពលរដ្ឋឲ្យពិចារណា ដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួន និង ប្រយោជន៍រួម ។ យោបល់ ឬ គំនិតអស់នេះមានតំលៃ ឬ អត់ សំរេចទៅលើអ្នកស្តាប់ គេវាយតំលៃ ។ បើអ្នកដឹកនាំប្រទេស ឬ បក្សហាមមិនឲ្យប្រជាពលរដ្ឋ ឬ សមាជិកមានសេរីភាពក្នុងទង្វើទាំងអស់នេះ គឺបានសេចក្តីថា ពួកអស់នេះជាពួកផ្តាច់ការ គង់តែស្រែកកុហកគេថា ខ្លួនគោរពលទ្ធិប្រជាធិបតេយ្យក៏ដោយ ។ នេះមិនលើកពីតម្លាភាពក្នុងការដឹកនាំប្រទេស និង បក្សនោះទេ ។ ការឲ្យមានតម្លាភាពក្នុងការដឹកនាំប្រទេស ឬ ក្នុងបក្ស អង្គការសង្គមស៊ីវិល បរទេសជាច្រើនដែលមកជួយខ្មែរបានអប់រំ និង ណែនាំឲ្យអ្នកដឹកនាំយើងអនុវត្ត ។ តែលទ្ធផលដូចជាមិនបានដូចការខំប្រឹងប្រែងរបស់គេទេ ឬមួយ ហាក់ដូចជា អ្នកដឹកនាំខ្មែរគ្មានវប្បធម៌អស់នេះ ឬមួយអ្នកដឹកនាំខ្មែរចាត់ទុកថា ប្រទេស ឬ បក្ស ជាសម្បត្តិផ្ទាល់ខ្លួន និង គ្រួសារខ្លួន ក្រុមខ្លួន លុយកាក់ ម៉្លោះហើយ មិនចាំបាច់មានតម្លាភាព ក្នុងការដឹកនាំទេ ។ នេះជាការយល់ច្រឡំមួយដ៏ធំក្នុងការដឹកនាំប្រទេស និង បក្ស ។

ឯចំណែកប្រកាសទ្រព្យសម្បត្តិផ្ទាល់ខ្លួន គង់តែច្បាប់មិនបង្ខំឲ្យប្រកាសជាសាធារណៈ ក៏ដោយ តែយើងជាអ្នកនយោបាយ ប្រកាសថាមិនពុករលួយ ហើយស្អាតស្អំ ត្រូវតែប្រកាសទ្រព្យសម្បត្តិ

របស់ខ្លួនជាសាធារណៈ ទោះជាមានក្ដី ក្រក្ដី អត់ក្ដី មិនមែនជាអាប់កិត្តិយសនោះទេ ឬ មួយមានគំនិតអាក្រក់ដូចពួកកាន់អំណាចដែរ?

បើលោក ហ៊ុន សែន យល់ថា ការរិះគន់របស់គណបក្សសង្គ្រោះជាតិ ជាពិសេស លោកឹមសុខ ថាមិនត្រឹមត្រូវទេ លោកក៏អាចឆ្លើយតបទៅវិញទៅ វាចប់បាត់ទៅហើយ ជាពិសេស លោក ហ៊ុន សែន មានមធ្យោបាយឆ្លើយតបទាំងអស់តាមបណ្ដាញ វិទ្យុ ទូរទស្សន៍ ។ល។ ដែលក្ដោបនៅក្នុងដៃ ។ តែមិនដូច្នេះទេ លោក ហ៊ុន សែនមិនចង់ឲ្យមានគេរិះគន់ទេ គឺលោកចង់ឲ្យគេទៅឃុបឃិត និង ស្រុបជាមួយលោក ។ លោក ហ៊ុន សែន មិនឆ្លើយតបទៅលើការរិះគន់នោះទេ ដើម្បីឲ្យ ប្រជាពលរដ្ឋវិនិច្ឆ័យ ។ តែបែរជាកំញើញថា «អនុប្រធានទី១រដ្ឋសភា គួរប្រយ័ត្នខ្លួន ព្រោះសមាជិកសភាភាគច្រើនជារបស់លោក ហើយសភាអាចបុកទម្លាក់ពីតំណែង បានដោយ សំឡេងភាគច្រើន ។» ការកំញើញនេះ គឺ លោក ហ៊ុន សែន អាចធ្វើបានពិតប្រាកដមែន ដោយតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា ទាំងអស់មិនបានបំពេញភារកិច្ចរបស់ខ្លួន ដើម្បី ការពារប្រជាពលរដ្ឋនោះទេ បែរជាទៅសំពះគាំទ្ររាជរដ្ឋាភិបាលទៅវិញ ។ ហើយនៅតាម គណៈកម្មការនានានៅរដ្ឋសភា ដែលសភាគណបក្សប្រជាជនកម្ពុជាជាប្រធាន ក៏មានគំនិតយ៉ាង ដូច្នេះដែរ ។ តើហេតុដូចម្ដេចលោកហ៊ុនសែន មិនចាត់វិធានការទៅ ចាំបាច់កំញើញទៅ តាម ខ្យល់ធ្វើអ្វី?

ការកំញើញរបស់លោក ហ៊ុន សែននេះ បញ្ជាក់ពីភាពមិនស្គាល់ច្បាស់របស់គាត់ពីអ្វីទៅ ដែលហៅថាលទ្ធិប្រជាធិបតេយ្យនោះ ។ ដូចជាពាក្យនីតិរដ្ឋ ដែលលោកហ៊ុន សែន ប្រកាស ថាលោកគោរព តែលោកទៅ «បារទឹក បារភ្លើង» ទាំងខាងយុត្តិធម៌ និង ទាំងខាង នីតិបញ្ញត្តិទៅទៀត ។

ចំណែកអ្នកកាន់អំណាច គេគ្មានវប្បធម៌តាមសំដីនោះទេ គឺមានច្រើនទៅលើវប្បធម៌ហឹង្សា គេចង់បំបិតយោបល់ប្រជាពលរដ្ឋ ដែលគ្នាតវ៉ាឲ្យអាជ្ញាធរគោរពសិទ្ធិរបស់គ្នា តែពួកអស់នេះ មិនយកត្រចៀកស្ដាប់ ឬ ភ្នែកមើលនោះទេ បែរជាប្រើអំពើហឹង្សាចាប់គ្នាដាក់គុក តែចំឡែកពួកអ្នក កាន់អំណាច នេះបែរជាស្រែកឲ្យអ្នកដទៃប្រើវប្បធម៌សន្ទនាទៅវិញ ។ គួរណាតែអាជ្ញាធរប្រើវប្បធម៌ សន្ទនា ពីព្រោះគេមានកំលាំង និងតំណាងច្បាប់ និង អំណាច តែបែរទៅវិញគេតែងតែ ប្រើវប្បធម៌ហឹង្សាទៅវិញ ។ ការដែលប្រើវប្បធម៌ហឹង្សានេះ នឹងអាចទទួល វប្បធម៌ហឹង្សាត្រឡប់ ទៅវិញ ពីព្រោះកំហឹងប្រជាពលរដ្ឋក៏មានកំរិតដែរ ដោយគ្នាសព្វថ្ងៃនេះ គុកក៏មិនខាន វាយក៏មិនឈឺទៅហើយ។

លិម គិម យ៉ា

តំណាងរាស្ត្រមណ្ឌលកំពង់ធំ

សមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្មនៃរដ្ឋសភា